ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ៦៩ សសណ.សរ

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ: ០៣៧៦
មកដល់ថ្ងៃទី២០ខែ១ឆ្នាំ១៥
ម៉ោង ៤:៣០ pm

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
## ថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៥

កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ វេលាម៉ោង៨និង៣០នាទីព្រឹក នៅអគារសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១–សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

២–សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ ។

៣–សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨។

៤–បញ្ហាផ្សេងៗ ។

### ១–សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

គណៈរដ្ឋមន្ត្រីបានសម្រេច៖

១.១-លុបចំណងជើងមាត្រាទាំងអស់នៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

១.២-នៅទំព័រទី២៖

-នៅមាត្រា៦ លុបខ្លឹមសារនៃវាក្យខណ្ឌទី២ ។

-នៅមាត្រា៧ លុបខ្លឹមសារនៃវាក្យខណ្ឌទី២ ។

១.៣-នៅទំព័រទី៨ មាត្រា២៨ កែសម្រួលទៅជា: " ក្នុងនាមរាជរដ្ឋាភិបាល គ.ជ.គ.ម. ជាអ្នកដឹកនាំ សម្របសម្រួលនិងអនុវត្តកិច្ចសហប្រតិបត្តិការ កិច្ចសហការ និងជំនួយជាប្រាក់កាស និងសម្ភារៈ

អន្តរជាតិក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ បូករួមទាំងការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិលើការងារគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបចម្រុះអន្តរជាតិ ក្នុងគ្រាមានគ្រោះអាសន្ន គ្រោះមហន្តរាយ ។"។

១.៤-នៅទំព័រទី៩ មាត្រា៣២ បន្ថែមវាក្យខណ្ឌមួយទៀតក្រោមចំណុចទី៣ ដែលមានខ្លឹមសារថា: " ការស្តារឡើងវិញដែលបានមកពីហិរញ្ញប្បទានឥតសំណង ឬឥណទានសម្បទាន ត្រូវប្រព្រឹត្តទៅស្របតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។"។

១.៥-នៅទំព័រទី១៣ ក្នុងជំពូកទី១០ បន្ថែមមាត្រាមួយទៀត គឺមាត្រា៤៧ ដែលមានខ្លឹមសារថា: " ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។"។

ក្រៅពីការកែសម្រួលខាងលើ គណៈរដ្ឋមន្ត្រីបានសម្រេចឯកភាពតាមសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គប្រជុំអន្តរក្រសួងបានរៀបចំស្នើឡើងមកនេះ។

**២-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧**

គណៈរដ្ឋមន្ត្រីបានសម្រេច៖

២.១-កែសម្រួលចំណងជើងសេចក្តីព្រាងច្បាប់ទៅជា: " សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ "។

២.២-នៅទំព័រ២ មាត្រាមួយ កែសម្រួលទៅជា: " មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖ "។

២.៣-នៅទំព័រទី៣ បន្ថែមមាត្រាថ្មីមួយទៀតគឺមាត្រា២៦ថ្មី ដែលមានខ្លឹមសារថា "អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់បៀវត្សរ៍ និងប្រាក់បំណាច់របស់មន្ត្រី និងបុគ្គលិកក្រោមឱវាទ ។

អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបង្កើតគម្រោងថវិកាចំណាយកិច្ចប្រតិបត្តិការសម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដែលមានកំណត់ចំណូល និងចំណាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ ថវិកាត្រូវកំណត់ច្បាស់លាស់នូវកម្រៃអាជ្ញាបណ្ណសម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗរួមទាំងវិធីគណនាកម្រៃអាជ្ញាបណ្ណ ព្រមទាំងបៀវត្សរ៍ និងប្រាក់បំណាច់ផ្សេងទៀត ដែលត្រូវទូទាត់ជូនសមាជិក និងមន្ត្រីជាន់ខ្ពស់របស់អាជ្ញាធរអគ្គិសនីកម្ពុជា។ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវដាក់គម្រោងថវិកានេះជូនទៅរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ "។

២.៤-នៅទំព័រទី៣ មាត្រា២៧ថ្មី វាក្យខណ្ឌចុងក្រោយ កែសម្រួលទៅជាៈ "ក្នុងករណីកែសម្រួលកម្រៃអាជ្ញាបណ្ណរហូតដល់កម្រិតអតិបរមារួចហើយ ប៉ុន្តែនៅតែពុំអាចទ្រទ្រង់កិច្ចប្រតិបត្តិការរបស់ខ្លួនបាន អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាល ដើម្បីពិនិត្យ សម្រេចកម្រិតអតិបរមានៃកម្រៃអាជ្ញាបណ្ណជាថ្មីឡើងវិញ "។

២.៥-នៅទំព័រទី៤មាត្រា២៧ថ្មី វាក្យខណ្ឌខាងលើ កែសម្រួលទៅជាៈ "កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវប្រព្រឹត្តតាមប្រព័ន្ធគណនេយ្យសាធារណៈ និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈជាធរមាន "។

២.៦-នៅទំព័រទី៤ បន្ថែមវាក្យខណ្ឌមួយទៀតនៅមាត្រា២៧ថ្មី ពីខាងលើមាត្រា២៨ថ្មីដែលមានខ្លឹមសារថាៈ "ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវគោរពទៅតាមច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន។"

២.៧-នៅទំព័រទី៤ វាក្យខណ្ឌចុងក្រោយ មាត្រា២៨ថ្មី កែសម្រួលទៅជាៈ " ក្នុងរយៈពេល១(មួយ)ខែ យ៉ាងយូរបន្ទាប់ពីធ្វើសវនកម្មរួច អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវដាក់របាយការណ៍ទាំងអស់ជូនទៅនាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ ។"។

ក្រៅពីការកែសម្រួលខាងលើ គណៈរដ្ឋមន្ត្រីបានសម្រេចឯកភាពតាមសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ ដែលក្រសួងរ៉ែ និងថាមពលបានរៀបចំស្នើឡើងមកនេះ។

**៣-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨**

គណៈរដ្ឋមន្ត្រីបានសម្រេច ឯកភាពតាមសេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ដែលក្រសួងមុខងារសាធារណៈ បានរៀបចំស្នើឡើងមកនេះ។

ទន្ទឹមនេះ គណៈរដ្ឋមន្ត្រីបានសម្រេចប្រគល់ភារកិច្ចជូនក្រសួងមុខងារសាធារណៈ កែសម្រួលបុព្វកថា ឬសេចក្តីផ្តើម ដោយបញ្ចូលលទ្ធផលដែលសម្រេចបាននៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាល ចាប់ពីដំណាក់កាលដំបូងរហូតដល់បច្ចុប្បន្ន ។

**៤-បញ្ហាផ្សេងៗ**

គណៈរដ្ឋមន្ត្រីបានសម្រេចៈ

៤.១.ធ្វើការកែតម្រូវចំពោះសេចក្តីថ្លែងការណ៍ដែលសម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងកន្លងទៅ នៅក្នុងពិធីបើកការដ្ឋានសាងសង់អគាររដ្ឋបាលសាលាខេត្តត្បូងឃ្មុំ ទាក់ទិននឹងការដំឡើងប្រាក់បៀវត្សជូនកងទ័ព នគរបាល និងមន្ត្រីរាជការស៊ីវិល ដូចខាងក្រោមៈ

-ប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលមានការកើនឡើងបន្តិច ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០១៥ ប៉ុន្តែ ចាប់ពីខែមេសា ឆ្នាំ២០១៥តទៅ នឹងមានការកើនឡើងយ៉ាងច្រើន។

-ប្រាក់បៀវត្សរបស់កងទ័ព និងនគរបាល មិនមានការកើនឡើងទេ ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០១៥ ប៉ុន្តែ ចាប់ពីខែមេសា ឆ្នាំ២០១៥ទៅ ប្រាក់បៀវត្សរបស់កងទ័ព និងនគរបាល នឹងមានការកើនឡើងយ៉ាងច្រើន។ អាស្រ័យហេតុនេះ សូមស្នើថ្នាក់ដឹកនាំខាងកងទ័ព និងនគរបាល ធ្វើការផ្សព្វផ្សាយជូនបងប្អូនកងកម្លាំងប្រដាប់អាវុធទាំងអស់ ឲ្យបានយល់ជ្រួតជ្រាប អំពីការកែតម្រូវខាងលើនេះ។

៤.២.ក្នុងរយៈពេល ០៣ខែ ចាប់តាំងពីខែមករា ដល់ខែមីនា ឆ្នាំ២០១៥ គ្រប់ក្រសួង ស្ថាប័នទាំងអស់ មិនត្រូវធ្វើការជ្រើសរើសក្របខ័ណ្ឌថ្មីឲ្យចូលបម្រើការងារក្នុងក្រសួង ស្ថាប័នសាមីនីមួយៗឡើយ ពីព្រោះគឺជារយៈពេលដែលក្រសួងមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ កំពុងធ្វើសមាហរណកម្មក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ថ្មីរបស់មន្ត្រីរាជការស៊ីវិល។

៤.៣.ណែនាំដល់មន្ត្រីរាជរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលត្រូវអញ្ជើញឲ្យចូលរួមមហាសន្និបាតវិសាមញ្ញរបស់គណបក្សប្រជាជនកម្ពុជា ដែលនឹងគ្រោងរៀបចំធ្វើនៅថ្ងៃទី៣០, ៣១ ខែមករា និងថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៥ខាងមុខ គឺត្រូវដាក់ពាក្យសុំច្បាប់សម្រាប់ថ្ងៃសុក្រ ទី៣០ ខែមករា ឆ្នាំ២០១៥ តាមនីតិវិធីដូចតទៅ៖ មន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវដាក់ពាក្យសុំច្បាប់ពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងមន្ត្រីថ្នាក់រាជធានី ខេត្ត ត្រូវដាក់ពាក្យសុំច្បាប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ចំពោះមន្ត្រីថ្នាក់ជាតិ ចាប់ពីអនុរដ្ឋលេខាធិការទៅដល់ទេសរដ្ឋមន្ត្រី ត្រូវដាក់ពាក្យសុំច្បាប់ពីឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ ហើយឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រីទាំងអស់ ត្រូវដាក់ពាក្យសុំច្បាប់ពីសម្តេចតេជោ នាយករដ្ឋមន្ត្រី។

៤.៤.ណែនាំដល់កងកម្លាំងប្រដាប់អាវុធទាំងអស់ដែលកំពុងឈរជើង នៅតាមតំបន់ព្រំដែនកម្ពុជា ថៃ ត្រូវបន្តរក្សាទំនាក់ទំនងល្អជាប្រចាំជាមួយភាគីថៃ ដើម្បីចៀសវាងឲ្យបាននូវការប៉ះទង្គិចដោយប្រដាប់អាវុធក្នុងទ្រង់ទ្រាយណាមួយ ដែលនឹងអាចកើតមានឡើង។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តឲ្យទទួលបានលទ្ធផលជាវិជ្ជមាន។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

ចម្លងជូនៈ

- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ